ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៤)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៤ ៨៣៨ នាក់ នៃរោងចក្រ សហគ្រាស ទាំង២៨ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីងនឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ០០០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២០ ០០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦០ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង២៨ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ៧កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧ ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ២៨ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 15 |
| 1 | ក្រុមហ៊ុន វូដុងអ៊ីនដាសស្ត្រៀល | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ដាប់ប៊ីលយូ អ៊ែនដ៏ ឌី កម្ពុជា | ភ្នំពេញ |
| 3 | ក្រុមហ៊ុន សៅលែន (ខេមបូឌា) | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហាណា (ខេមបូឌា) អ៊ីង | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 6 | ក្រុមហ៊ុន អ៊ី ហ្គាមេន ខូអិលធីឌី | កណ្តាល |
| 7 | ក្រុមហ៊ុន យ៉ង់ ស៊ីង | កណ្តាល |
| 8 | ក្រុមហ៊ុន ហ្គោលហ្វេម ស្តារ អេនធើប្រាយ (ខេមបូឌា) លីមីធីត | កណ្តាល |
| 9 | ក្រុមហ៊ុន បូវយើ ហ្គាមេន ព្រីនធីង(ខេមបូឌា)ខមភេនី លីមីធីត | កណ្តាល |
| 10 | ក្រុមហ៊ុន អេហ្វ យូ ជី ហ្គាម៉ិន (ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 11 | ក្រុមហ៊ុន ផាតធេច(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 12 | ក្រុមហ៊ុន ជេ អេស ឌី ថេកស្តាយ (ខេមបូឌា) | តាកែវ |
| 13 | ក្រុមហ៊ុន លី ឈាង ឧប | កំពង់ចាម |
| 14 | ក្រុមហ៊ុន អរិន មេនូហ្វេកឆឺរីង ( ខ្មែរ ) | ព្រៃវែង |
| 15 | ក្រុមហ៊ុន ស៊ីសុផុន ហុង សេង ស្ពែតវែរ ឯ.ក | បន្ទាយមានជ័យ |
| ខ. វិស័យទេសចរណ៍ | | 13 |
| 16 | ក្រុមហ៊ុន ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន អេមខេត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 18 | សណ្ឋាគារ រ៉ាហ្វិល រ៉ូយ៉ាល់ | ភ្នំពេញ |
| 19 | ក្រុមហ៊ុន អលឡើម (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 20 | ក្រុមហ៊ុន ថាលាស | ភ្នំពេញ |
| 21 | ក្រុមហ៊ុន កូបេ យៃភែននីស វែស្ទូវែន | សៀមរាប |
| 22 | ផ្ទះសំណាក់ សាតូអង្គ | សៀមរាប |
| 23 | ក្រុមហ៊ុន ដឹ ប្លែក សាន់ រេសចឺរេន អេន បារ ខូ អិលធីឌី | សៀមរាប |
| 24 | ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស | សៀមរាប |
| 25 | ក្រុមហ៊ុន កាឡាស ខម(ខេមបូឌា)ភីធីអ៊ី អិលធីឌី (សណ្ឋាគារ អង្គរ អេរ៉) | សៀមរាប |
| 26 | សណ្ឋាគារ អង្គរ ហូតែល គ្រុប(សណ្ឋាគារ អប្សរា ផាឡេស) | សៀមរាប |
| 27 | ក្រុមហ៊ុន អានឡុង អេហ្សេត អ៊ិវេសមេន | សៀមរាប |
| 28 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |